គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា
Committee for Free and Fair Elections in Cambodia
ខុមហ្វ្រែល COMFREL

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.

ទស្សនៈវិស័យ ៖ ដើម្បីឱ្យការបោះឆ្នោតមានអត្ថន័យ ដែលផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋ

ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣

# សេចក្តីប្រកាសព័ត៌មាន (កែតំរូវ)
# ស្តីពី
# ការរកឃើញបឋម ភាពមិនប្រក្រតីនៅថ្ងៃស ថ្ងៃបោះ និងរាប់សន្លឹកឆ្នោត

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) សូមធ្វើការដាក់បង្ហាញភាពមិនប្រក្រតីដែលបានរកឃើញកំឡុងថ្ងៃស ថ្ងៃបោះ និងរាប់សន្លឹកឆ្នោត នៅលើផែនទីក្នុងគេហទំព័រ៖ www.comfrel.org ឬ www.cambodianvotervoice.org។

របាយការណ៍របស់អ្នកសង្កេតការណ៍បណ្តាញខុមហ្វ្រែលបានបង្ហាញថា ចំនួននៃភាពមិនប្រក្រតីនៅកំឡុងថ្ងៃស ថ្ងៃបោះ និងរាប់សន្លឹកឆ្នោតមាន១០,៨២៧ករណី (ថ្ងៃសមាន១៩២ករណី, កំឡុងពេលបោះឆ្នោតមាន ១០,៣៩៨ករណី និងកំឡុងពេលរាប់សន្លឹកឆ្នោតមាន២៣៧ករណី) ដែលបានកើតឡើងភាពមិនប្រក្រតីនៅប្រមាណ២,០៥៩ការិយាល័យបោះឆ្នោត ក្នុងចំណោម៥,៦៥២ការិយាល័យដែលទទួលបានពីអ្នកសង្កេតការណ៍ ដោយភាពមិនប្រក្រតីនេះបានកើតឡើងនៅគ្រប់ខេត្ត/រាជធានី ដូចជា កំពង់ចាម ៣,១៤៨ករណី, ភ្នំពេញ ១,៨២២ករណី,កំពត ៨៦០ករណី, កណ្តាល ៧៧៥ករណី, ព្រៃវែង ៤៣៥ករណី, តាកែវ ៤៣១ករណី, សៀមរាប ៤១៣ករណី, ពោធិសាត់ ៣៨៣ករណី, ប៉ៃលិន ៣៥៥ករណី, បន្ទាយមានជ័យ ៣៥៤ករណី, បាត់ដំបង ៣៣៥ករណី, ក្រុងព្រះសីហនុ ២៦៥ករណី, កោះកុង ២០២ករណី និងខេត្តផ្សេងៗទៀតក្រោម២០០ករណី។ ភាពមិនប្រក្រតីនេះមិនទាន់បានរាប់បញ្ចូលរបាយការណ៍អង្កេតរបស់អ្នកសង្កេតការណ៍ខុមហ្វ្រែលដែលជាបណ្តាញអង្គការសង្គមស៊ីវិលដែលបានធ្វើការសង្កេតក្នុងថ្ងៃបោះ និងរាប់សន្លឹកឆ្នោត។

***សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖***

១. កញ្ញា **គង់ រ៉ាវីន** អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ៖ ០១២ ៦៥៤ ៩៥០

<u>បេសកកម្ម</u> ៖ បេសកកម្មរបស់ខុមហ្វ្រែល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការបោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/ **ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួក ទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត។